ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែមករា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែមករានេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦១២ ០៨៥ហ.ត ស្មើនឹង ១៣៣,២៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិកររងផលប៉ះពាល់។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែមករានេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦១២ ១៥៨ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២៤៥ហ.ត ស្មើនឹង០,៦៩% និងដោយគ្រឿងយន្តចំនួន ៦០៧ ៩១៣ហ.ត ស្មើនឹង៩៩,៣១%
- ផ្ទៃដីសាបសម្រេចបានចំនួន ២៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦១២ ០៨៥ហ.ត ស្មើនឹង ១៣៣,២៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត លើសឆ្នាំមុន ៣៧ ៥៧២ហ.ត។

#### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំង

-ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៦៦ ៥៤៥ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២៨៤ ២១៤តោន និងទទួលទិន្នផលគិតជាមធ្យម ៤,២៧១តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៣ ៧៦១ហ.ត ស្មើនឹង៩០,៤៨% នៃផែនការចំនួន ៣៧ ៣១២ហ.ត តិចជាងឆ្នាំមុន ៧៤៦ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧២ ៨១៤ហ.ត ស្មើនឹង៨៥,៩០% នៃផែនការចំនួន ៨៤ ៧៧០ហ.ត លើសឆ្នាំមុន ១ ៤៥៧ហ.ត។

#### ១.៤ ការនាំចេញផលិតផលកសិកម្ម

១.៤.១ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៣៤ ២៧៣តោន មានការថយចុះចំនួន ១៦ ១៧៧តោន (-៣២,០៧%) តិចជាងបរិមាណនាំចេញក្នុងខែមករា ឆ្នាំ២០២០ មានចំនួន ៥០ ៤៥០តោន។ បាននាំចេញទៅកាន់ទិសដៅចំនួន ២៨ប្រទេស

ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ មានចំនួន ១៦ ១៦៣តោន ប្រទេសបារាំងឈរលំដាប់ទី២ មានចំនួន ៣ ៧២៣តោន ប្រទេសហ្គាបុងឈរលំដាប់ទី៣ មានចំនួន ៣ ៥៧០តោន ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ មានចំនួន ៣ ១៨៤តោន ប្រទេសអូស្ត្រាលីឈរលំដាប់ទី៥ មានចំនួន ៩០៨តោន សាធារណរដ្ឋឆែកឈរលំដាប់ទី៦ មានចំនួន ៨៩៥តោន ប្រទេសអេស្ប៉ាញឈរលំដាប់ទី៧ មានចំនួន ៧៨៦តោន ប្រទេសណេដឺឡែនឈរលំដាប់ទី៨ មានចំនួន ៧៥២តោន ប្រទេសនូវែលហ្សេឡង់ឈរលំដាប់ទី៩ មានចំនួន ៥៦២តោន និងប្រទេសម៉ាយុតឈរលំដាប់ទី១០ មានចំនួន ៥០៣តោន ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៣៦ក្រុមហ៊ុន។

១.៤.២ ការនាំចេញកសិផលផ្សេងៗ

បរិមាណនាំចេញផ្លែចេកស្រស់ចំនួន ៤០ ៩៥៦តោន ទៅកាន់ប្រទេសចិន វៀតណាម សិង្ហបុរី និងប្រទេសជប៉ុន។ ផ្លែស្វាយស្រស់ចំនួន ១១ ៦៣៧តោន ទៅកាន់ប្រទេសវៀតណាម ថៃ កូរ៉េ សិង្ហបុរី និងហុងកុង។ គ្រាប់ពោតចំនួន ៤៤ ៤៧១តោន ទៅកាន់ប្រទេសកូរ៉េ តៃវ៉ាន់ ថៃ និងប្រទេសវៀតណាម។ គ្រាប់ស្វាយចន្ទីចំនួន ៣ ១៨៣តោន ទៅកាន់ប្រទេសវៀតណាម ចិន និងប្រទេសថៃ។ ម្រេចចំនួន ២តោន ទៅកាន់ប្រទេសស៊ុយអ៊ែត ជប៉ុន បែលហ្សិក អាមេរិច និងប្រទេសកូរ៉េ។ ម្ទេសស្រស់ចំនួន ១៦ ២៥២តោន ទៅកាន់ប្រទេសថៃ។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៤ ១៥៩ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៤៩៧ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦៦៣ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៥៧ ៩៧២តោន កើនឡើងចំនួន ១៤ ៣៦០តោន ស្មើនឹង៣៣% ធៀបនឹងខែមុន និងកើនឡើងចំនួន ៨ ៥៨៨តោន ស្មើនឹង១៧% ធៀបខែមករា ឆ្នាំ២០២០។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ៥២ ៧១១តោន កើនឡើងចំនួន ១០ ០៤៤តោន ស្មើនឹង២៤% ធៀបនឹងខែមុន និងកើនឡើងចំនួន ៤ ៤០៩តោន ស្មើនឹង៩% ធៀបខែមករា ឆ្នាំ២០២០។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យមក្នុងខែមករា គឺ ១ ៦០៣ដុល្លារ/តោន កើនឡើងចំនួន ៨៦ដុល្លារ/តោន ស្មើនឹង៦% ធៀបនឹងខែមុន និងកើនឡើង ២៣២ដុល្លារ/តោន ស្មើនឹង១៧% ធៀបខែមករា ឆ្នាំ២០២០។
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែមករា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៥០០៛/គ.ក្រ ដល់ ៥ ៩០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៣០០៛/គ.ក្រ ដល់ ២ ៨៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បាននិងកំពុងវាយតម្លៃ និងផ្ទៀងផ្ទាត់គម្របព្រៃឈើលើឆ្នាំ២០២១
- បានទាញយករូបភាពផ្កាយរណប (Landsat8) ក្នុងឆ្នាំ១៩៧៣ ១៩៧៥ ១៩៧៦ ១៩៧៨ ១៩៧៩ និងឆ្នាំ២០២១ សរុបចំនួន ៥២ផ្ទាំង ដើម្បីពិនិត្យសិក្សាប្រវត្តិគម្របព្រៃឈើ
- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៦៣គ្រឿង និងយានយន្តចំនួន ៧៩គ្រឿង ជូនក្រុមហ៊ុនចំនួន ៣ក្រុមហ៊ុន
- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ២មានកូនឈើចំនួន ១០ ០០០ដើម អុសចំនួន ១០ ០០០ស្ទែរ និងឬស្សីចំនួន ៩៦,៨៥០តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានសហការជាមួយអង្គការ FFI ដើម្បីចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១២គ្រឿង នៅតំបន់ជួរភ្នំក្រវាញក្នុងខេត្តកោះកុង ដោយថតជាប់សត្វដំរីព្រៃចំនួន ២៨ក្បាល ប្រើសចំនួន ១១ក្បាល ឈ្លូសចំនួន ៩ក្បាល ស្វាគ្រោសចំនួន ៣២ក្បាល កាំប្រម៉ាចំនួន ១ក្បាល និងជ្រូកព្រៃចំនួន ៨ក្បាល
- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនលោក សេង សារឿង ចំនួន ១ច្បាប់ មានស្វាក្ដាមចំនួន ២០ក្បាល សម្រាប់ដឹកចេញពីរមណីយដ្ឋានភ្នំសន្ទុកឆ្ពោះទៅកាន់ភូមិពោធិ៍ខាវ ឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៨ច្បាប់ ក្នុងនោះ ១៧ច្បាប់ សម្រាប់ការថែរក្សាសត្វក្រចៀកកាំ និង១ច្បាប់ទៀតសម្រាប់ថែរក្សាសត្វឃ្មុំដែលមានទីតាំងស្ថិតនៅខេត្តកោះកុង ពោធិ៍សាត់ កំពត និងខេត្តមណ្ឌលគិរី។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ៨កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្ដាមសរុបចំនួន ៧០ ៦២២ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៣ ៩៨៩ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦៤៧ក្បាល (បក្សី៥៧ប្រភេទ ថនិកសត្វ៤៥ប្រភេទ និងល្មូន១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៩៧ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣៩ក្បាល ស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៥៤ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០ នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥ គឺ អារ៉ែង ឆាយរាប តំបន់ស្ការក្រពើស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវក្រាលក្រួសក្រហមសរុបប្រវែង ៧៣៦ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ០,៣៧ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៤ហ.ត ចម្ការឈើដាំទំហំ ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បាននិងកំពុងស្វែងរកទីតាំងសុវត្ថិភាពសម្រាប់អនុវត្តការងារគម្រោងដាំឈើប្រចាំឆ្នាំ២០២១ ដោយកំណត់យកទីតាំងអនុវត្តនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ឆ្នាំង និងខេត្តព្រះវិហារ

- បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ១០ ៥០០ដើម ក្នុងថ្នាលបណ្ដុះកូនឈើចំនួន៦ទីតាំង ក្នុងខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្ដាលចំនួន ០២ កន្លែង។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៤៦ករណី ដោយពិន័យអន្តរការណ៍ចំនួន ១៥ករណី និងបញ្ជូនទៅតុលាការចំនួន ៣១ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ក្រុមហ៊ុនចំនួន ១បាននាំចេញផលិតផលរានទេវតាទៅក្រៅប្រទេសចំនួន ៨ម៣
- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ២មានជ័រទឹកចំនួន ១០៨តោន។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ៦៣ ៣៨០ ២៥២រៀល និង ៨៩១ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាព

សត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៦ករណី។ រាជធានី-ខេត្តចំនួន ១៩ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៧ ៦៨០លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ប្រជុំពិភាក្សាស្តីពីការពិនិត្យ និងកែសម្រួលលើឯកសារជំងឺបេស្តជ្រូកអាហ្វ្រិក (ASF) និង ការងារអនុវត្តថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២១។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្ម-ពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទ-ល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៣ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ២ ១៩៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ជំងឺផ្តាសាយបក្សីផ្ទុះចំនួន ១កន្លែងនៅភូមិព្រែកតាប្រេង ឃុំព្រែងនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ជាយត្រីអនុវត្តបានចំនួន ១ ៣០០តោន ស្មើនឹង១០,៨៣% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ១០០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៨ ៨០០តោន ស្មើនឹង៥,៤៥% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ១ ៨០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៦ ១០០តោន ស្មើនឹង៤,២១% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ៤០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៧ ៦៥០តោន ស្មើនឹង៥,៨៨% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ កើនឡើងចំនួន ៥០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្កាអនុវត្តបានចំនួន ១៨ ៩៦០តោន ស្មើនឹង៣,៩៤% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ កើនឡើងចំនួន ៣ ១៦០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៩ ៤០០ក្បាល ស្មើនឹង២,៨៥% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ២០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥ ០៥០ ០០០កូន ស្មើនឹង៥,៥៧% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបខែមករា ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ៥០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៥ ៦០០តោន ស្មើនឹង៧% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ៣៨០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៩០០តោន ស្មើនឹង៧,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ កើនឡើងចំនួន ១០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣ ០០០ ០០០លីត្រ ស្មើនឹង៥,៤៥% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ៤០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២០៩ករណី ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ១០ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២០៧ករណី និងសមុទ្រចំនួន ២ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ២៦៣តោន ស្មើនឹង១,៧៥% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ២៣១តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ៨៩តោន ស្មើនឹង១,៧៨% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបខែមករា ឆ្នាំ២០២០ ថយចុះចំនួន ១១តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ៣១ ៥៣៣ ៦០០រៀល ស្មើនឹង៨,៧៩% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបខែមករា ឆ្នាំ២០២០ កើនឡើងចំនួន ១៨ ៤២៧ ៦០០រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- ចុះត្រួតពិនិត្យលើការងារអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ

- ចុះស្រាវជ្រាវពាក្យបណ្តឹងរបស់ឈ្មោះ អួម វ៉ាន់ សុំអន្តរាគមន៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង ការប្រគល់ដីស្រែភោគៈមិនទានចុះបញ្ជីទំហំ ៤ហ.ត នៅភូមិតាប៉ោញ ឃុំព្រៃតាអី ស្រុកស្វាយទាប ខេត្តស្វាយរៀង

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផលិតផលជលផលនាំចេញ នាំចូល និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ

- ចុះស្រាវជ្រាវពាក្យបណ្តឹងរបស់មន្ត្រីរាជការនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប ពីភាពមិនប្រក្រតីលើការដឹកនាំ និងការគ្រប់គ្រងរបស់លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប

- បានទទួលពាក្យបណ្តឹងចំនួន ២ករណី

- ការទទួលពាក្យបណ្តឹងតាមរយៈគេហទំព័រលើប្រព័ន្ធអិនធើណេត (www.gi.maff.gov.kh) ចំនួន ១ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១៩៦ករណី

- ការចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៩លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧១៣ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៨៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៨១ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៤៥ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៨៨៩ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥៧ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៣៣ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៤៦នាក់ (ស្រី១ ៤១៨នាក់ ស្មើនឹង២៤,២៥%) រួមមាន៖

+ អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩១៩នាក់ (ស្រី៨២៤នាក់ ស្មើនឹង២៨,២២%)

+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩២៧នាក់ (ស្រី៥៩៤នាក់ ស្មើនឹង២០,២៩%)

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកចំនួន ៧នាក់ ក្នុងនោះច្បាប់លំហែមាតុភាពចំនួន ១នាក់ ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ៣នាក់ និងច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៣នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១នាក់

- បានរៀបចំប្រកាស ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន០១នាក់

- បានរៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការចូលនិវត្តន៍ដោយបាត់បង់កាយសម្បទាវិជ្ជាជីវៈចំនួន ១នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២៣៩នាក់ (ស្រី ៧១នាក់) ក្នុងនោះ៖

+ ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២៣៩នាក់ (ស្រី៧១នាក់)

+ ការបណ្តុះបណ្តាលក្រៅប្រទេសពុំមាន។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានឆ្លើយតបទៅក្រសួងទេសចរណ៍លើការពិនិត្យ និងគាំទ្រលើសេចក្តីព្រាងផ្លូវការផែនការមេសម្រាប់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០២០-២០៣៥

- បានអនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល បញ្ចេញដោះដូរពូជស្រូវផលសារចំនួន ៦ ៩៦៩គ.ក្រ

- បានរៀបចំប្រមូលផ្តុំឯកសារវិនិយោគសម្បទានដីសេដ្ឋកិច្ចតាមបណ្តាក្រុមហ៊ុនដើម្បីថែរក្សាទុក

- បានលើកសំណើស្នើសុំថវិកា ចុះធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១

- បានធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១

- បានចុះតាមដានការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០២០-២០២១

- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍នៅរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានីខេត្តចំនួន២៥ និងបានបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានបញ្ចេញអាណត្តិបើកប្រាក់ខែពីក្រសួងសរុបចំនួន ៤ ៧៥១,៧លានរៀល

- បានរៀបចំសំណើសុំពិនិត្យគាំទ្រផែនការសកម្មភាពឆ្នាំ២០២១ របស់កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្មក្រោមហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប

- បានរៀបចំលិខិតសំណើបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ៣

- បានចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី

- បានចុះពិនិត្យ វាយតម្លៃសម្រាប់ការប្រគល់ទទួលលើការអនុវត្តកិច្ចសន្យាចំនួន ២គម្រោង ការងារជួសជុលអគាររបស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការងារជួសជុលទ្រុងសត្វ ទំនប់ស្អាក់ទឹកនៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ ការងារសាងសង់ចំណតរថយន្តរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ និងការងារជួលជុលអគាររដ្ឋបាលរបស់រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ២០២០។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ (ឆ្នាំគោល) និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខាបច្ចេកទេស ថែទាំ និងជួសជុល

- បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០២១-២០២៣ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការរដ្ឋ-ទេយ្យបុរេប្រទានឆ្នាំ២០២១

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំចំនួន ២លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- បានចូលរួមសិក្ខាសាលាចំនួន ២លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- បានសម្របសម្រួលរៀបចំកិច្ចប្រជុំចំនួន ១លើក

- បានសម្របសម្រួលរៀបចំការចុះហត្ថលេខារវាងអង្គការ FAO ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ១លើក

- បានសម្របសម្រួលរៀបចំទស្សនកិច្ចចំនួន ១លើក

- បានសម្របសម្រួលរៀបចំការចុះតាមដាន និងវាយតម្លៃចំនួន ១លើក។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៩ក្រុមហ៊ុន សរុបចំនួន ២៩៤មុខ

- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១២ក្រុមហ៊ុន

- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២ក្រុមហ៊ុន

- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៤ក្រុមហ៊ុន សរុបចំនួន ១៣សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានពិនិត្យ និងផ្តល់មតិចំនួន ២ករណី។

### ១៣.៤ ការងារអនុវត្តច្បាប់

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ៥ខេត្ត គឺខេត្តព្រះវិហារ ឧត្តរមានជ័យ កំពង់ចាម កំពត និងខេត្តតាកែវ ត្រួតពិនិត្យលើ៣៣ដេប៉ូ ដោយពិន័យចំនួន ៧ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានសម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្តាលលើគេហទំព័រផុសចំនួន ១៦ព័ត៌មាន

- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋាន-កិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១៩ក្បាល/ច្បាប់

- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកមានអ្នកចូលអានចំនួន ៩ ៦៧៣ដង/នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចុះសិក្សាពីតម្រូវការកសិករលើការផ្សព្វផ្សាយកសិកម្ម តាមរយៈប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្មនៅខេត្តកំពង់ឆ្នាំង និងខេត្តព្រះវិហារ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នៅខេត្តបន្ទាយមានជ័យ

- បានចុះទៅថត Video បទយកការណ៍ចំនួន ១ប្រធានបទ

- បានធ្វើការផលិត Video និងចាក់ផ្សាយឡើងវិញចំនួន ២ប្រធានបទ

- បានផលិត Video នាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមប្រជុំពិនិត្យពិភាក្សាលើសេចក្ដីព្រាងប្រកាសស្ដីពីនីតិវិធីនៃការស្នើសុំបង្កើតរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ
- បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងគុណភាពចំណីអាហារតាមប្រព័ន្ធអ៊ិនធើណេត
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា
- បានចុះបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពបុគ្គលិករោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី ជ័យ សំបូរ នៅខេត្តកំពង់ធំលើប្រព័ន្ធ HACCP ការប្រើប្រាស់ឧបករណ៍ សម្ភារ និងគ្រឿងម៉ាស៊ីន
- បានចុះសិក្សាស្រាវជ្រាវដំណាក់កាលស៊ីជម្រៅអំពីគំរូអាជីវកម្មរបស់ក្រុមហ៊ុន សហគមន៍កសិកម្ម និងបណ្ដុំកសិករនៅខេត្តព្រះវិហារ ដោយសហការជាមួយមជ្ឈមណ្ឌលសិក្សាគោលនយោបាយ
- បានចុះពិនិត្យសិក្សាទីតាំងសមស្របសម្រាប់បើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលនេសាទសមុទ្រ
- បានធ្វើវិភាគសំណាកចំណីសត្វ និងវត្ថុធាតុដើមផលិតរបស់រោងចក្រធំៗចំនួន ១៧រោងចក្រ។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្ដុះបណ្ដាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ និងទស្សនកិច្ចសិក្សារបស់គណៈកម្មការតម្រង់ទិស និងគណៈកម្មការប្រតិបត្តិនៃសម្ព័ន្ធកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានៅខេត្តបាត់ដំបង
- បានចុះជ្រើសរើសទីតាំងពិសោធន៍នៅខេត្តតាកែវ
- បានចុះទំនាក់ទំនងជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ការងារពិសោធន៍ឆ្នាំ២០២១
- បានចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ
- បានអនុវត្តការងារពិសោធន៍នៅស្ថានីយស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកោះកេរ្ដិ៍នៅខេត្តព្រះវិហារ
- បានចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរដ្ឋនៅស្ថានីយស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកោះកេរ្ដិ៍នៅខេត្តព្រះវិហារ
- បានចុះប្រមូលគ្រាប់ពូជត្រសក់ ត្រសក់ស្រូវ និងល្ពៅនៅខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការប៉ាន់ប្រមាណប្រព័ន្ធនវានុវត្តន៍កសិកម្មក្នុងក្របខ័ណ្ឌគម្រោង ការអភិវឌ្ឍសមត្ថភាព និងស្ថាប័នក្នុងប្រព័ន្ធនវានុវត្តន៍កសិកម្មដែលទទួលបានការឧបត្ថម្ភថវិកាពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FAO)
- បានចុះធ្វើការសិក្សា និងវាយតម្លៃសក្ដានុពលនៃប្រព័ន្ធជីវឧស្ម័ន ធ្វើបទបង្ហាញអំពីរបាយការណ៍វាយតម្លៃសង្ខេបអំពីគម្រោងសាងសង់ប្រព័ន្ធជីវឧស្ម័ន និងពិភាក្សាអំពីនីតិវិធីការគាំទ្រហិរញ្ញប្បទានក្នុងដំណាក់កាលដំបូងជូនម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូកនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះសីហនុ និងសហការដឹកនាំចុះរៀបចំថតវីដេអូផ្សព្វផ្សាយមជ្ឈមណ្ឌលជាមួយកសិដ្ឋាន M's pig និងចុះពិនិត្យដំណើរការប្រព័ន្ធចម្រោះឧស្ម័ននៅក្នុងកសិដ្ឋាននោះតែម្ដង។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៩៤៣នាក់ (ស្រី៣៨៧) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស
- បាននិងកំពុងដំណើរការជ្រើសរើសនិស្សិតថ្នាក់បរិញ្ញា និងបរិញ្ញារងឆ្នាំទី១ និងចំនួននិស្សិតសរុបសម្រាប់ឆ្នាំសិក្សាឆ្នាំ២០២០-២០២១នឹងត្រូវកំណត់រួចរាល់ក្នុងខែកុម្ភៈ

- បានរៀបចំកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាអស់រយៈពេលជាច្រើនឆ្នាំបានបញ្ចប់ និងបញ្ជូនទៅសុំការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡា

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗកំពុងដំណើរការ គឺការពិសោធន៍ចិញ្ចឹមគោទឹកដោះ ការពិសោធន៍ចិញ្ចឹមបង្គា ការពិសោធន៍បង្កាត់ពូជមាន់ ការសិក្សាពិសោធន៍ថ្នាំបណ្តេញសត្វល្អិត ការសិក្សាស្រាវជ្រាវបង្កាត់កេសរក្ងួល ការពិសោធន៍ដំណាំព្រីង ការសិក្សាពិសោធន៍ផលិតម្សៅឫស្សី ការពិសោធន៍ដំណាំសាគូពងពស់ ការបណ្តុះជាលិការុក្ខជាតិ ការពិសោធន៍ពូជស្មៅអ៊ីស្រាអែល ការពិសោធន៍ចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធន៍ចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៦៥៦នាក់ (ស្រី២៨៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍កូន កូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍កូនចំនួន ១២ចម្ការពិសោធន៍

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- យកសំណាក និងវិភាគ LD ចម្ការពិសោធន៍ការប្តូរផ្ទាំងចៀរចំនួន ១ស្មើនឹង២០សំណាក

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យគ្រប់ចម្ការពិសោធន៍

- វាស់ទំហំដើមចម្ការពិសោធន៍ឥទ្ធិពលនៃការស្រោចស្រពលើការលូតលាស់ និងទិន្នផលកៅស៊ូ

- ត្រួតពិនិត្យការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រកៅស៊ូសន្លឹក

- បានធ្វើតេស្តកៅស៊ូ RSS របស់ វ.ស.ក.ក ចំនួន ៨សំណាក ដើម្បីវាយតម្លៃគុណភាពនៃការកែច្នៃកៅស៊ូ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦១២ ០៨៥ហ.ត ស្មើនឹង ១៣៣,២៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត ដោយការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៦៦ ៥៤៥ហ.ត ទទួលបរិមាណផលសរុបចំនួន ២៨៤ ២១៤តោន និងទទួលទិន្នផលគិតជាមធ្យម ៤,២៧១តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំ-កសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួត-ពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូល

ចរិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០២១
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត
- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)
- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់
- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ
- បាននិងកំពុងរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាម

រយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។/.

ថ្ងៃ សុក្រ ៧ រោច ខែ មាឃ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**